**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

**ផ្ញើជូន**

**ឯកឧត្តម មុត ខៀវ រដ្ឋលេខាធិការ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ**

**ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ !**

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា លោកស្រី **ខៀវ រ៉ាវី** ដែលត្រូវជាកូនបង្កើតរបស់ឯកឧត្តមបានទទួលមរណភាព នៅថ្ងៃអាទិត្យ ១០កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ វេលាម៉ោង២២:៣៨ នាទី ក្នុងជន្មាយុ៤៣ឆ្នាំ ដោយរោគាពាធ។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមសម្តែងនូវការសោកស្តាយស្រណោះអាឡោះអាល័យជាទីបំផុតជាមួយ**ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ដែលបាត់បង់កូនស្រីជាទីស្រលាញ់ដ៏ជ្រាលជ្រៅ និងប្រកបដោយកតញ្ញូចំពោះឪពុកម្តាយ និងក្រុមគ្រួសារ។ ទោះបីរូបកាយលោកស្រី **ខៀវ រ៉ាវី** បានបាត់បង់ទៅពិតមែន តែកុសលកម្ម កិត្តិយសសេចក្តីថ្លៃថ្នូររបស់លោកស្រី នឹងនៅស្ថិតស្ថេរក្នុងសន្តានចិត្តញាតិមិត្តជិតឆ្ងាយទាំងអស់ជានិច្ចនិរន្តរ៍។

ខ្ញុំនិងភរិយាសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជះបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់**លោកស្រី ខៀវ រ៉ាវី** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម មុត ខៀវ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ និងភរិយា។

ថ្ងៃពុធ ១៣កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**